**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ០២៦៦ ក.ស.ភ.

ថ្ងៃ អង្គារ ១០កើត ខែផល្គុន ឆ្នាំរកា ព.ស.២៥៦០
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមីនា គ.ស.២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## មហាសន្និបាតភាគហ៊ុនិកលើកទី ២ របស់កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)

**កំពង់ផែស្វយ័តភ្នំពេញ** (ក. ស. ភ.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" របស់ ក. ស. ភ. ទាំងអស់មេត្តាជ្រាបថា÷ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំជាវិសាមញ្ញលើកទី៥ អាណត្តិទី៦ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ ក. ស. ភ. នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ តាមការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date) : **ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧**

២. កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី២ : **ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧**

៣. ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី២: សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាល ទីស្នាក់ការកណ្តាល (ចំណតផែ TS៣) ដែលស្ថិតនៅអាគារលេខ ៦៤៧ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤. របៀបវារៈនៃមហាសន្និបាតភាគហ៊ុនិកលើកទី២ រួមមាន៖

| | |
|---|---|
| ពីម៉ោង ៨:០០-៩:០០ | ចុះវត្តមានអ្នកចូលរួម |
| ពីម៉ោង ៩:០០-៩:៣០ | ប្រកាសហេតុ |
| ពីម៉ោង ៩:៣០-១០:៣០ | - មតិស្វាគមន៍របស់ប្រធានមហាសន្និបាត<br>- បទបង្ហាញស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តការងារឆ្នាំ២០១៧<br>- សំណួរ-ចម្លើយ |
| ពីម៉ោង ១០:៣០ -១០:៤៥ | មតិបិទកម្មវិធី |

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក. ស. ភ.) ឬ អាចទទួលបានលិខិតអញ្ជើញនៅទីស្នាក់



ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៩២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

ការកណ្ដាលរបស់ ក. ស. ភ. ដែលមានអាសយដ្ឋាននៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្ដីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាទៅបញ្ជាក់ពីការចូលរួមនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណវិនិយោគិន និង អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែន ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ រៀងរាល់ថ្ងៃធ្វើការ។

- បញ្ជាក់ ÷ ភាគហ៊ុនិកដែលអញ្ជើញមកចូលរួមមហាសន្និបាតភាគហ៊ុនិក សូមយកមកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់ ក. ស. ភ.។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក ធនាគារ អេស៊ីលីដា ភីអិលស៊ី និងកំពង់ផែស្វយ័តភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនង ដូចខាងក្រោម÷

**១.ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន: អគារលេខ៦១ មហាវិថីព្រះនរោត្ដម សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ : (៨៥៥) ២៣ ៩៩៨ ៧៧៧ (Ext : ៨៣១៦៧)
- ទូរសារ : (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ : (៨៥៥) ១៥ ៦០០ ៧៤៣
- សារអេឡិចត្រូនិក : lim.an@acledabank.com.kh

**២.កំពង់ផែស្វយ័តភ្នំពេញ**

- អាសយដ្ឋានអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទដៃ៖ ០១០ ៤៤៤ ៣៦៧ /០១០ ៤៤៤ ៣៧៥ /០១០ ៤៤៤ ០១៧
- អ៊ីម៉ែល ៖ ppapmpwt@online.com.kh

**ជ.គណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ២**

**ប្រធាន**

**ហ៊ី-ប្រាវី**

**ចម្លងជូន÷**

-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក)
-សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.
-សវនករផ្ទៃក្នុងរបស់ ក. ស. ភ.
-សវនករឯករាជ្យរបស់ ក. ស. ភ. - ក្រុមហ៊ុន KPMG

*"ដើម្បីជូនជ្រាប"*

-ធនាគារ អេស៊ីលីដា ភីអិលស៊ី
(ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)

*"ដើម្បីសហការផ្សព្វផ្សាយ"*

-ឯកសារ-កាលប្បវត្តិ



ទីចាត់ការកណ្ដាល: អគារលេខ ៦៤៩ តំ:វិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh